ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

RECEIVED
11 JAN 2013
BY:..................

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :......០០៧/១៣.........ក.ប.ការ

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣

## សេចក្តីជូនដំណឹង
### ស្តីពី
### ការឈប់សម្រាកការងាររបស់កម្មករនិយោជិត ចូលរួមព្រះរាជពិធីដង្ហែ និងថ្វាយព្រះភ្លើង គោរពព្រះវិញ្ញាណក្ខន្ធ ព្រះបរមសព ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារបានជ្រាបថា យោងតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ១២ សរណន. ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១២ ស្តីពីការឈប់សម្រាកការងារមន្ត្រីរាជការ បុគ្គលិក និយោជិត កម្មករចូលរួម ព្រះរាជពិធីដង្ហែ និងថ្វាយព្រះភ្លើង គោរពព្រះវិញ្ញាណក្ខន្ធ ព្រះបរមសព ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ សូមលោក លោកស្រី ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ អនុញ្ញាតឲ្យកម្មករនិយោជិតបានឈប់សម្រាកដោយមានប្រាក់ឈ្នួលចំនួន ០២ ថ្ងៃ តាមកាលបរិច្ឆេទ ដូចខាងក្រោម:-

១- ថ្ងៃ សុក្រ ទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៣ ព្រះរាជពិធីដង្ហែព្រះបរមសព

២- ថ្ងៃ ចន្ទ ទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១៣ ព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខន្ធ និងថ្វាយព្រះភ្លើង។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ព្រមទាំងកម្មករនិយោជិតទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

រដ្ឋមន្ត្រី

វង សូត

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- កាលប្បវត្តិ - ឯកសារ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩